# ការសំរេចចិត្តសាងសង់ឡជីវឧស្ម័ន ជាជំរើសដ៏ត្រឹមត្រូវរបស់កសិករ

កម្មវិធីឡជីវឧស្ម័នជាតិនៃប្រទេសកម្ពុជា បានដំណើរការបន្ទាប់ពីមានការចុះអនុស្សរណៈរវាងក្រសួងកសិកម្ម ជាមួយនឹងអង្គការអភិវឌ្ឍន៍របស់ប្រទេសហូល្លង់ (SNV) កាលពីខែ មីនា ឆ្នាំ ២០០៦។ កម្មវិធីនេះបាន និងកំពុង ដំណើរការនៅបណ្តាខេត្តចំនួនប្រាំ គឺ ខេត្តកណ្តាល កំពង់ចាម ស្វាយរៀង តាកែវ និងខេត្តកំពង់ស្ពឺ។

ឡជីវឧស្ម័ន គឺជាបច្ចេកវិជ្ជាទំនើបមួយដែលបំលែងលាមកសត្វ មនុស្ស ទៅជាឧស្ម័នសំរាប់ប្រើប្រាស់ក្នុងការ ចំអិនអាហារ និងដុតបំភ្លឺ នៅពេលយប់។ ក្រៅពីនេះ កាកសំណល់ឡជីវឧស្ម័ន អាចប្រើប្រាស់ជា ជីធម្មជាតិសំរាប់ដំណាំ និងជាចំណីបន្ថែមសំរាប់ត្រីទៀតផង។ ឡជីវឧស្ម័នដែលកម្មវិធីណែនាំ គឺជាប្រភេទសង់ពីស៊ីម៉ងត៍មានរាងមូល (បច្ចេកវិជ្ជាមកពីប្រទេសឥណ្ឌា) ដែលមានឈ្មោះ **"ឡជីវឧស្ម័ន មិត្តកសិករ"** អាចប្រើប្រាស់បានរហូតដល់ពី ២០-២៥ ឆ្នាំ ប្រសិនបើសំភារៈសាងសង់មានគុណភាពល្អ គោរពតាមបទដ្ឋាន មានការប្រើប្រាស់បានត្រឹមត្រូវ និងថែទាំបានល្អ។

គំរូឡដែលកម្មវិធីបាន និងកំពុងណែនាំមាន ៥ ទំហំខុសៗគ្នា គឺ ៤ ៦ ៨ ១០ និង ១៥ ម$^{៣}$។ បរិមាណលាមកសត្វដែលត្រូវការប្រចាំថ្ងៃ គឺប្រែប្រួលទៅតាមទំហំឡ ដែលក្នុងនោះទំហំតូចបំផុតត្រូវការ២០ គីឡូក្រាម។



## តើឡជីវឧស្ម័នមានសារៈប្រយោជន៍អ្វីខ្លះ?

ការសាងសង់ឡជីវឧស្ម័នបានផ្តល់សារៈប្រយោជន៍ ច្រើនផ្នែកដល់កសិករ ដូចជា:

### ១. ផ្នែកសេដ្ឋកិច្ច

- កសិករលែងចំណាយថវិកាក្នុងការទិញអុស ធ្យូង ប្រេងកាត និងទិញហ្គាស។
- កសិករចំណេញពេលវេលាសំរាប់រកចំណូលពីប្រភពផ្សេងៗទៀតបាន។
- កសិករអាចកាត់បន្ថយចំណាយទៅទិញជីគីមី ដោយជំនួសដោយការប្រើប្រាស់កាកសំណល់ឡ។
- កសិករបានកាត់បន្ថយលើការចំណាយថវិកាសំរាប់ព្យាបាលជំងឺដែលបណ្តាលមកពីផ្សែង។

- ធ្វើអោយកសិករបន្ថែការចិញ្ចឹមសត្វនៅតាមមូលដ្ឋាន ដែលជាមុខចំណូលមួយយ៉ាងសំខាន់។
- ធ្វើអោយកសិករបង្កើនប្រាក់ចំណូលដែលបានពីការប្រើប្រាស់កាកសំណល់ឡលើការងារដាំដុះដំណាំ និងការចិញ្ចឹមត្រី

**២. ផ្នែកបរិស្ថាន**

- កសិករបានចូលរួមចំណែកក្នុងការកាត់បន្ថយការកាប់ព្រៃឈើ។
- ធ្វើអោយបរិស្ថានក្នុងដីរបស់កសិករកាន់តែប្រសើរ (ជីជាតិដី និងទំរង់ដីកាន់តែប្រសើរ) ។
- កាត់បន្ថយការបំភាយឧស្ម័នមេតាន និង ឧស្ម័នកាបូនិច ទៅក្នុងបរិយាកាសដែលបង្កដោយលាមកសត្វ ដែលមិនបានគ្រប់គ្រងត្រឹមត្រូវ។
- កាត់បន្ថយបាននូវក្លិតស្អុយ ដែលចេញពីការចិញ្ចឹមសត្វទ្រង់ទ្រាយធំ ( ល្បាយកាកសំណល់ឡ គ្មានក្លិនស្អុយទេ) ។
- គ្រាប់ស្មៅ និងភ្នាក់ងារបង្ករោគមួយចំនួនដែលមាននៅក្នុងលាមកសត្វ ត្រូវបានសំលាប់ក្នុងដំណើរការបំបែកធាតុក្នុងឡ ( ដោយសារតែកំដៅ និងលក្ខខ័ណ្ឌគ្មានខ្យល់) ។
- ធ្វើអោយបរិយាកាសជុំវិញផ្ទះកាន់តែប្រសើរតាមរយៈការប្រមូលលាមកសត្វទាំងឡាយដាក់ក្នុងឡ។
- ធ្វើអោយបរិស្ថានក្នុងផ្ទះចៀសផុតពីផ្សែង ជាហេតុធ្វើអោយសំលៀកបំពាក់ និងជញ្ជាំងផ្ទះកខ្វក់ ។
- ធ្វើអោយចង្ក្រានបាយមានអនាម័យល្អ (គ្មានផេះ និង ខ្មៅគូថឆ្នាំង) ។

**៣. ផ្នែកសង្គម**

- អាចកាត់បន្ថយបាននូវបន្ទុកដ៏ធ្ងន់ធ្ងររបស់ស្រ្តី និងកុមារ ក្នុងការស្វែងរកអុសសំរាប់ដុត។
- ធ្វើអោយកុមារមាបឱកាសទៅសិក្សាបានច្រើន(មិនខ្វល់ពីការដើររកអុស)
- កាត់បន្ថយពេលវេលារបស់ស្រ្តីក្នុងការបង្កាត់ភ្លើងពេលដាំស្លម្តងៗ។
- អាចកាត់បន្ថយបានន្ធូគ្រោះ អគ្គីភ័យដែលបង្កដោយរងើកភ្លើង។
- ស្រ្តីមានពេលវេលាច្រើនក្នុងការចូលរួមសកម្មភាពការងារផ្សេងៗរបស់សង្គម។
- មានពន្លឺចង្កៀងសំរាប់ជួយដល់ការសិក្សារបស់កុមារ និងអាចសំរួលដល់ការធ្វើការងារផ្សេងៗនៅពេលយប់។
- ធ្វើអោយកសិករមានភាពហ៊ឺហា ដោយមានភ្លើងបំភ្លឺផ្ទះ និងហ្គាសសំរាប់ដុតចំអិនអាហារ

***តើកសិករនឹងទទួលបានអ្វីខ្លះពីកម្មវិធី ប្រសិនបើសំរេចសាងសង់ឡនៅពេលនេះ?***

- ចំពោះកសិករក្នុងខេត្តគោលដៅ ដែលសំរេចចិត្តសាងសង់ឡជីវឧស្ម័ន កម្មវិធីនឹងផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ចំនួន ១០០ ដុល្លា (ទំហំណាក៏ដោយ) ។
- កម្មវិធីជួយតាមដាន និងត្រួតពិនិត្យលើការងារសាងសង់របស់ជាង
- កម្មវិធីជួយផ្តល់ការធានាគុណភាពរយ:ពេលពីរឆ្នាំ
- កម្មវិធីជួយផ្តល់សេវាកម្មក្រោយពេលសាងសង់ឡដូចជា បង្រៀនពីរបៀបប្រើប្រាស់ និង ការថែទាំឡ ការ គ្រប់គ្រង និងប្រើប្រាស់កាកសំណល់ឡ និងជួយសំរួលដល់ការដោះដូរគ្រឿងបំពាក់នៅពេលខូចខាត ។ល។
- កម្មវិធីលើកទឹកចិត្តដល់កសិករ ដែលអាចទំនាក់ទំនងរកអ្នកជាវឡ ដោយអោយ ៥ ដុល្លា សំរាប់ឡជីវឧស្ម័នមួយ។

**រៀបរៀងដោយ ផង់ ឌា**

**មន្រ្តីផ្សព្វផ្សាយសំណល់ឡជីវឧស្ម័ន នៃកម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ**